នាងហាក់ផ្ទុះសំណើចមួយខឹកវិញដែរហើយសម្លឹងគេតប។

មានអីត្រូវខ្លាច?

ឃើញនារីសម្លឹងមិនដាក់ ជួនសើចជួនស្មើខាងប្រុសញាក់ស្មាតាមបែបអឺរ៉ុប មាត់ស្រដីបន្ថែមពីលើសម្ដីអះអាងរបស់ខ្លួន៖

«មិនអ៊ីចឹង? បើទូកចេញហើយ ខាងណោះក៏ទៅស្ទឹងត្រែង ខាងយើងក៏ទៅណោះដែរ មានអីធ្ងន់?»

«ផ្ទះគីម៉ាល់នៅស្ទឹងត្រែងដែរ?!»

នាងសួរហាក់រីករាយ ស្រាប់តែខាងប្រុសទម្លាក់ពន្លឺភ្នែកទៅជាស្រពោន......

## បណ្ដាំចុងក្រោយ

៤០ថ្ងៃមុន......

គីម៉ាល់កំពុងឈានជើងប្រមាត់ជណ្ដើរ។

«បង! ទូរសព្ទខលពីភ្នំពេញ!»

នៅពេលចិត្តប្រុសស្អាតកំពុងលង់គិតដល់ទេសភាព គ្របដណ្ដប់លើដីនិងសមុទ្រពេលខ្លួននឹងលោតទៅលើអាកាសនាពេលបន្តិចទៀតនេះ គេមិនចង់គិតអ្វីយកចិត្តទុកដាក់អ្វីនឹងអ្នកជុំវិញខ្លួនផង កុំថាឡើយអ្នកនៅភ្នំពេញដែលគេបានបោះបង់ចោល។

កីឡាផ្សងព្រេងកំពូលៗនៅឌូបៃ រាល់ប្រកួតប្រជែងពេញទៅដោយការភ័យខ្លាចគឺជាជីវិត៨ឆ្នាំចុងក្រោយនេះ របស់គីម៉ាល់។

គេងាកមុខចេញពីអ្នកហុចទូរសព្ទជាសញ្ញាថា «មិនទទួល!» ហើយបែរទៅចុចទ្វារកញ្ចក់សារជាថ្មីព្រោះការលោតចេញពីយន្តហោះ Skydive ឌូបៃ ពីកម្ពស់ ១៣,០០០ ហ្វីតកំពុងរង់ចាំគេ។

«បងពិសិដ្ឋស្លាប់ហើយ!»

គីម៉ាល់ផ្អៀងក ងាកមករកអ្នកនិយាយ។ សម្រាប់គេមិនបាច់ផ្ទួនឃ្លាដដែលពីរដងទេ។ គេដឹងថា អ្វីមួយកំពុងទង្គិចបេះដូងគេស្មើនឹង ទឹកមុខស្លេកស្លាំងនៃអ្នកដែលកំពុងហុចឧបករណ៍មក។

គេមិនទទួលទូរសព្ទតែភ្នែកគេរេទៅជាមួយភាពខ្លោចផ្សា។ ដៃគេទំនងជាញ័រ បានជាគេមិនលើកវាមកប្រើ ឬមួយគេមិនចង់ហាមាត់និយាយនឹងអ្នកនៅភ្នំពេញ?

អ្នកកាន់ទូរសព្ទទំនងយល់ចិត្ត គេក្ដោបឧបករណ៍នោះក្នុងបាតដៃហើយឱនមកខ្សឹបៈ

«បងសិដ្ឋគាំងបេះដូង! ពេទ្យមកមិនទាន់ទេ! តាំងពីយប់មិញ!»

គីម៉ាល់ ទម្លាក់ភ្នែកឃើតៗសម្លឹងដី។

គេមិនមាត់អ្វីទេ តែភ្នែកគេក្រហមឡើងៗ។ មនុស្សម្នាអាចឃើញភាពតឹងតែងតាមរយៈស្នួរដង្ហើមរបស់គេ។

ទឹកមុខខ្មៅរោលមួយរំពេចនេះហាក់បីដូចជាបទបញ្ជាបង្គាប់អ្នកក្បែរខ្លួនឱ្យផ្ដាច់ចោលខ្សែទំនាក់ទំនងដែលកំពុងរង់ចាំឆ្លងដែនវេហាសៃនឆ្ងាយនោះ ដោយមិនចាំបាច់ចេញវាចា។

ដោយទឹកមុខរាវែក អ៊ុនដែលជាកូនចៅជំនិត គីម៉ាល់តែងយកមកនៅក្បែរខ្លួនម្នាក់នេះ ដាច់ចិត្តលើកទូរសព្ទមកនិយាយមុនពេលផ្ដាច់ៈ

«ជម្រាបគាត់រួចហើយ!»

ថាចប់ក៏ចុចបិទទូរសព្ទ។ អ៊ុន មានអារម្មណ៍ថា ម្ចាស់ប្រុសកំពុងប្រញាប់ប្រញាល់ក្នុងការរុញទ្វារកញ្ចក់ចាកចេញ។ គេមិនបានបោះបង់ចោលការទម្លាក់ខ្លួនក្នុងល្បឿនខ្ពស់ ២០១ គីឡូម៉ែត្រក្នុងមួយម៉ោងនោះទេ ទោះបីដំណឹងមរណភាពបាននឹងកំពុងកម្ចាត់អ្វីៗទាំងអស់នៅទីនេះ។

«បងស័ក កុំ!»

នេះជាអ្នកជំនិតម្នាក់ទៀតឈ្មោះ វុធ ហាមាត់ហាម។ ស័កជាឈ្មោះខ្មែររបស់គីម៉ាល់។ ៨ឆ្នាំហើយ គេមិនដែលវិលទៅភ្នំពេញទេ សូម្បីពេលប៉ាគេស្លាប់ ហើយក្រោយមក ប្អូនប្រុសសំណព្វបានរៀបការ។ គេមិនដែលគិតថាមានហេតុផលណាមួយអាចធ្វើឱ្យគេត្រឡប់ទៅរកទឹកដីដែលបន្សល់អនុស្សាវរីយ៍ឈឺចាប់អនេកអនន់នោះឡើយ មិនថាមានរឿងអ្វីកើតឡើង។

ប៉ុន្តែថ្ងៃនេះមនុស្សជាទីស្រឡាញ់ចុងក្រោយ បានរលត់សង្ខារទៅហើយ។ ពិសិដ្ឋប្អូនប្រុសតែមួយគត់មានសុខភាពខ្សោយពីកំណើតមក គ្រប់គ្នាមិនចម្លែកទេចំពោះដំណឹងនេះប៉ុន្តែ បេះដូងបងប្រុសនៅតែគ្រាំ។

«អ្នកមានទម្ងន់លើសពី ១០០ គីឡូក្រាមមិនអាចចូលរួមលោតឡើយសូមអធ្យាស្រ័យ»

នារីប្រកាសនិយាយពាក្យដដែលៗខ្ទរស្ទូរសព្ទ។ គេនៅតែបន្តដើរផុតទ្វារទៅកាន់ស្ថានីយ៍លក់សំបុត្រមួយនៅមិនដល់៣ម៉ែត្រពីមុខខ្លួន។

តាំងពីពេលទទួលយកសំបុត្ររហូតដល់ចុចប៊ូតុងចាក់សោអាវខ្សែចង្វាក់សម្រាប់លោត គីម៉ាល់មិននិយាយអ្វីទាំងអស់ក្រោមភាពព្រួយបារម្ភយ៉ាងខ្លាំងនៃមនុស្សជំនិតទាំងឡាយ។

គេកម្រនិយាយ ហើយរឹតែនិយាយតិចតួចបំផុតរាល់ដែលពេលគេឈឺចាប់។

អ្វីដែលស្តាប់ទៅដូចជាសុបិនអាក្រក់សម្រាប់មនុស្សភាគច្រើន នៅតែជាក្តីសុបិនល្អរបស់គេ ព្រោះសកម្មភាពផ្សងព្រេង បានជួយឱ្យបេះដូងថ្មរបស់គេអាចលោតរំភើបមួយគ្រាៗឡើងវិញ ពុំនោះទេ គេស្លាប់យូរហើយ។

ដើម្បីលោតចេញពីរចនាសម្ព័ន្ធខ្ពស់បំផុតមួយ នៃល្បែង Skydive ឌូបៃនិង XDubai ជាទៀងទាត់ បាននាំមកនូវភាពភ័យខ្លាច ការសើចរំភើប និងអារម្មណ៍ស្រើបស្រាលដល់គេ តែថ្ងៃនេះវាគ្មានអ្វីរំជួលរីករាយទេ។

នៅតាមផ្លូវដែលធ្លាក់ចុះ សឹងភ្លេចដកដង្ហើម គេគិតម្នាក់ឯងថា បើស្លាប់មានអីមិនល្អ រស់នៅបន្ត ក៏មានអ្វីខ្លះដែលអាចធ្វើឱ្យចិត្តលោតកម្រើកបានទៀត បើមនុស្សចុងក្រោយដែលមានវត្តមានក្នុងបេះដូងយើង បានទៅចោលយើងទៅហើយ ?

ចេញពីទីនោះ គេកាន់តែពិបាកសូម្បីតែនឹងលេបបាយ។

ក្តីសង្ឃឹមបន្តក្នុងបណ្តាថ្ងៃកន្លងៗមកទៀត គឺការធ្វើឱ្យជីវិតលិចទៅក្នុងភាពរំភើប កំដរបេះដូងក្រៀមក្រោះឱ្យមានជីវិតជីវ៉ាអាចលោតដំណើរការមកវិញខ្លះ គឺការបំភ្លេចខ្លួនឯងទៅក្នុងកាមារម្មណ៍។

ជាទូទៅ អំពើពេស្យាចារនៅអារ៉ាប់រួម គឺខុសច្បាប់។

មិនថាអំពើពេស្យាចារលួចលាក់អាចកំពុងតែរីករាលដាលជាពិសេសនៅឌូបៃនិងអាប៊ូដាប៊ី ក៏ប៉ុន្តែអាជ្ញាធរនឹងធ្វើពិន័យធ្ងន់ណាស់សូម្បីតែមិនទាន់រៀបការហើយបណ្តើរគ្នាឡើងសណ្ឋាគារក្តី។

ក្រោយៗមក បានឡើងយន្តហោះមកសិង្ហបុរី ប្រទេសថៃ កោះតៃវ៉ាន់ ហុងកុង ហើយសម្លាប់ពេលវេលាខ្លួនឯងនៅកន្លែងអនាចារថ្នាក់ខ្ពស់ៗដែលមានតែក្រុមមានលុយចាយមិនខ្វះ ទើបអាចប្រើប្រាស់សេវាកម្មបាន។

ដូចជារាត្រីមួយនេះ ដោយសារគេមានសាច់ដុំដូចអត្តពលិក មុខមាត់ស្រស់សង្ហា ទោះគេមិនចំណាយស្នាមញញឹម ក៏មនុស្សស្រីជាច្រើនបានបណ្តាក់គ្នាចូលមកកំដរបេះដូងនាយ។

«Are you from Dubai?»

នារីនេះក្មេងណាស់ ក្មេងសឹងគីម៉ាល់មិនចង់ប៉ះពាល់នាង ប៉ុន្តែនាងហាក់ថ្មីករឿងជំនួយផ្នែកភេទ។ ដោយរត់ម្រាមដៃរបស់ខ្លួនតាមបណ្តោយលង្វែកទ្រូងប្រុសស្អាតនាងនិយាយទាំងពេញចិត្តពេញថ្លើមលើភ្ញៀវម្នាក់នេះ៖

«ចូលចិត្តស្នេហារបៀបអត់មានពាក្យសន្ទនាហ្មែន?!»

នារីនេះមិនអាចមើលឃើញអត្ថន័យពិតក្នុងកែវភ្នែកល្ហល្ហេវល្វឹងល្វើយឆ្ងាយដាច់សង្វែងរបស់គេទេ។ រាងកាយនាងត្បិតតែសិចស៊ីចំពោះកែវភ្នែកទាំងគូនេះ ហើយត្បិតតែធម្មជាតិនៃអ័រម៉ូនបុរសនេះមានតម្រូវការភេទខ្ពស់ឡើងៗរាល់ពេលគេឈឺចាប់ឬក្នុងទោសៈ តែគេមិនបានបាត់បង់ស្មារតីឡើយ។

«បើដឹងហើយ ចំណាយពេលអត់ប្រយោជន៍ដល់ណាអ្ហេះ?!»

សំឡេងបុរសនេះសិចស៊ីដុតចិត្តអស្ចារ្យណាស់ទៅហើយ កុំថាឡើយសម្ដីគេខ្សោយៗដាស់កាមារម្មណ៍កម្រិតនេះទៀត។

សោភិនី ឱនទៅកៀក រភ្នែកសម្លឹងប្រស្រីពណ៌ខ្មៅរលោង ទំហំធំ ហើយបង្អួសភ្នែកមកទើរនឹង បបូរមាត់ដែលពោរពេញទៅដោយស្នាមឱស្នោកគ្រោក ។

គីម៉ាល់តែងតែសើចគ្មានសំឡេងរបៀបនេះជាមួយដៃគូប្លែកមុខរាល់ពេលណាដែលគេចង់បណ្តោយខ្លួនឯងឱ្យកប់បាត់សន្លឹមទៅក្នុងសភាវៈរំជួលចិត្ត។

«រហន់ម្លេះ?»

នាងនិយាយអង់គ្លេសហើយរំអួយ។

ស្រីក្មេង ស្អាតហើយល្វត់ល្វន់ ទន់កន្លៀក ថែមទាំងចេះប្រើសំឡេងតំអួញ អាជីពទៀត តើគីម៉ាល់រត់រួចពីអារម្មណ៍រំភើបដែរទេ?

«បងឯងជាបុរសស្អាតបំផុតដែលខ្ញុំធ្លាប់បានបម្រើដឹងនៅ?!»

ស្រីតូចនេះបន្ថែមប្រយោគជ្រាម៉ា ដាក់ក្លែមលាយពន្លឺភ្នែកអំនួតដែលបាននាយក្នុងក្នុងដៃ និងកន្ទុយភ្នែកប្រកាសសង្គ្រាមឱដងគ្នា ដោយប្រើរាងកាយជំនួសបេះដូង ព្រោះនៅមិនទាន់មានស្នាម។

នឹងបោសសម្អាតនាងឱ្យរាបដល់ដី ប្រហែលជាអាចជួយគេឱ្យបំភ្លេចទុក្ខវេទនាផងទាំងពួងនៅលើលោកនេះបាន?

បុរសលើកហត្ថាខាងស្ដាំប្រលែងលើស្មាសរលោង ហើយផ្ដើមបិទភ្នែក មុនពេលប្រើដៃម្ខាងទៀតរត់ចរច្រប់ពាសពេញឯកសិទ្ធិនានានៃអ្នកនៅពីមុខខ្លួន។ សំឡេងគ្រហឹមរបស់ម៉ាស៊ីនតណ្ហា កម្ដៅកាន់តែខ្លាំងទោះមិនចេញពីបេះដូង តែជាតម្រូវការរាងកាយដែលមិនយូរទេ វានឹងរំលងទៅ។

ត្រូវបានស្រីស្អាតថ្នាក់ថ្នម បុរសនេះទុកចោលស្មារតីរិះគិតផងទាំងពួង រហូតដល់នាងលោបប្បូរមាត់មករក ទើបគេស្រវាស្រទេញងាកគេចចេញ។

«កុំ! ខ្ញុំមិនចូលចិត្ត»

គឺម៉ាល់មិនដែលផ្លាស់ប្ដូរអណ្ដាតជាមួយនារីណាទេ។ នេះជាអាថ៌កំបាំងនៃជីវិតភេទរបស់បុរសរសាត់អណ្ដែតម្នាក់នេះ ចំណែកគេក៏ខ្លួនឯងក៏មិនដឹងចម្លើយដែរថា «ហេតុអ្វី»។

«កាច់រាងណាស់!»

នារីនោះរញ៉ាំរញ៉ូវព្រោះនាងទំនងជាចង់បានអនុស្សាវរីយ៍មួយ ជាជាងភេទសម្ព័ន្ធធម្មតា តែម្ចាស់ទីពិសេសនោះ មិនទាន់បង្ហាញខ្លួនក្នុងជីវិតគេនៅឡើយ គឺម៉ាល់មានតួនាទីថែទាំវាសម្រាប់តែនាងទេដឹង?

មេឃាខាងក្រៅជះពន្លឺក្រហម បន្ថែមកម្ដៅរំលងផ្ទាំងកញ្ចក់។

សំឡេងទឹកហូរនៅក្នុងបន្ទប់ទឹក ហាក់លាន់មករំខានដល់ក្បែរៗត្រចៀកផ្ដាច់ចោលការគេង ដេកលក់យ៉ាងសុខស្រួលរបស់ប្រុសស្អាត។

គេបើកភ្នែកឃឹតៗ ជ្រួញចិញ្ចើមជ្រើវថ្ងាសព្រោះនៅរោយត្របកភ្នែក។ សម្លៀកបំពាក់និងស្បែកជើងខ្ចាត់ខ្ចាយលើកំរាលព្រំនៃផ្ទៃបន្ទប់ដែលកាលពីយប់មិញ ពោរពេញទៅដោយក្លិននៃសេចក្ដីស្នេហាទិញដោយប្រាក់។

ការស្រវឹងជាមួយក្លិនខ្លួនមនុស្សស្រីមិនអស្ចារ្យសម្រាប់ប្រុសម្នាក់នេះគ្មានរហូតដល់ថ្ងៃបន្ទាប់ឡើយ។

គេច្រត់ដៃទាំងពីររុញខ្លួនឯងឡើង ចាកចោលការគេងផ្ដាប់លើពូកសទន់កប់ដើមទ្រូង។ ពីបន្ទប់ទឹកដែលមិនបានបិទទ្វារជិត នារីដែលតាមសម្លឹងមើលនាយដោយកែវភ្នែកពណ៌ខ្មៅជាសញ្ញាសោកស្ដាយរាត្រីដែលមានជាមួយនាយ ។

«ទីនេះ តែងតែពោរពេញទៅដោយអំពើអាក្រក់ៗដែលពួកមនុស្សប្រុសប្រើលើពួកយើង! យប់មិញ ក៏ជាពេលវេលាដំបូងដែល ខ្ញុំបានសប្បាយចិត្តនិងស្គាល់ក្ដីសុខ!»

នាងនិយាយតិចៗពីក្រោយខ្នងនាយ ដែលកំពុងចំកោងខ្លួនហាត់ប្រាណលើកម្រាលព្រំ។ ដដែលជាដដែល នាងនៅតែបង្ហាញឫកពាថា គេនេះជាបុរសស្អាតបំផុតមិនធ្លាប់បានជួប ជួបហើយមិនចង់ដាក់ភ្នែក។

បបូរមាត់គេមិនត្រឹមកំណាញ់ស្នាមថើបសូម្បីតែនិយាយក៏មិននិយាយច្រើនដែរ។

គេដឹងថានារីនេះឆ្លងកាត់ការលំបាកវេទនា តែជីវិតមនុស្សគ្រប់គ្នាមានវិញ្ញាសារាងខ្លួន។ ហោចណាស់នាងបានដោះដូរតណ្ហាសត្វលោកជាមួយខ្លួន ទោះវាមិនមែនជាស្នេហា មិនសមយកមកគិតអំពីអ្វីទាំងអស់ តែចិត្តគេនៅតែមានករុណាធម៌។

បុរសដាក់លុយខ្លះទៅលើគម្របក្រៅនៃកាបូបក្រហមរបស់នាង ហើយបញ្ជោះ

«ទៅចុះ! ខ្ញុំមានការទៀត!»

គេហានិយាយស្ដីស្រាលៗសុភាពតែនាងដឹងថា នាងមិនបានជួបគេទៀតទេ។

នារីនោះយកលុយឡើងមករាប់ទាំងសប្បាយអរ ហើយប្រមូលសម្ភារៈចាកចេញ។

លើកលែងតែបេះដូងគីម៉ាល់ប៉ុណ្ណោះ ដែលអាចនៅជាមួយគេគ្រប់ពេលវេលា។ គេឈ្ងោកលុបមុខម្នាក់ឯង ក្នុងអារម្មណ៍ថា កំពុងតែមានសេរីភាព មានអារម្មណ៍ល្អជាងមុន ហើយសន្សឹមៗគេងើបមកសម្លឹងបបូរមាត់របស់ខ្លួនក្នុងផ្ទាំងកញ្ចក់។

«លើលោកនេះមានស្រីណាម្នាក់ ក្មេងស្អាត ចិត្តល្អហើយចង់ថើបឯង ទាំងមិនត្រូវការលុយមិនខ្វល់ថាឯងមកពីណាជាអ្នកណានោះទេអាKemal អាស្រមៃ!»

សម្រាប់មួយវិនាទីគិតបែបឆោតៗល្ងង់ៗគ្មានអ្នកណាដែលថាមិនធ្លាប់ទេ។ ចំណែកឯមនុស្សឯកោមិនដែលសមចិត្តដូចនាយ រឹតតែគិតល្ងង់ៗច្រើនដងមកហើយ គ្រាន់តែគ្មានអ្នកណាដឹង។

តុៗ......

ស្នូរគោះទ្វារមិនខ្លាំងទេតែរំខានច្រើនដងណាស់!

គេដើរយឺតៗតម្រង់មកជាមួយកន្សែងពណ៌សលើស្មា។

ទឹកមុខគេនៅពីក្រោយទ្វារដែលរបើកសន្សឹមៗ មិនបានបង្ហាញថា យប់មិញឆ្លងកាត់រលូននូវរាត្រីត្រេកត្រអាលភ្លេចអស់ព្រួយកង្វល់ទេ។

ស្រីស្អាតបំផុតក្នុងក្លឹបនេះហើយ នៅមិនអាចឱ្យគាត់ញញឹមវិញទៀត?

អ៊ុនសួរចិត្តខ្លួនឯងស្ងាត់ៗ។

«ខ្ញុំឆែកមើល ក្រែងបងត្រូវការអី!»

ក្មែកគេសម្លឹងរេរកមើលស្រីក្មេងហើយបន្ទាប់មកដើរចូលត្រឹកៗតាមពីក្រោយចៅហ្វាយពេលដឹងថាគេនៅម្នាក់ឯង។

«យើងត្រឡប់ទៅវិញ!» គេបញ្ជាតិចៗធ្វើឱ្យកូនចៅលាន់មាត់សួរ៖

«ទៅស្រុកខ្មែរ?!»

អ៊ុនតបទាំងអរ។

គីម៉ាល់ បង្អង់ការពាក់អាវយឺតពណ៌ប្រផេះដែលទើបក្រាលគ្របបានពាក់កណ្តាលខ្លួន។ ពាក្យ «ស្រុកខ្មែរ» បានក្លាយជាអាវុធសម្ងាត់មិនដឹងត្រជាក់ឬក្តៅ ធ្លាប់បុកបេះដូងនាយជារឿយៗពេលនិមិត្ត ឬបានឮអ្នកណាម្នាក់រំឭកដល់។

គេមិនបែរមកមើល គូសន្ទនាទេ តែតាមស្រមោលលើផ្ទាំងកញ្ចក់វេរ៉ង់ដា ទឹកមុខគេបញ្ចេញចម្លើយស្រេចហើយថា អ៊ុននិយាយ«មិនត្រូវ»។

អ៊ុនទីទើរ មុនពេលតាំងចិត្តនិយាយបន្ថែម៖

«មុនស្លាប់ បងសិដ្ឋផ្ញើសារសំឡេងមកច្រើនណាស់!»

គីម៉ាល់ពាក់អាវបន្ត។ គេមិនមានប្រតិកម្មបញ្ជាក់ថាគេមិនបដិសេធក៏មិនប្រាកដថាចង់ស្តាប់។ ហេតុតែរឿងនោះអ៊ុនយល់ថាសំខាន់ ដូច្នេះទោះមានទោសប៉ុនណាគេត្រូវតែរាយការណ៍៖

«ខ្ញុំយល់ថាសារទាំងអស់នោះសំខាន់ណាស់បងគីម៉ាល់!»

គេក្រឡេកមើលទៅកន្លែងដែលទូរសព្ទខ្លួនកំពុងហុចសំដៅមក។ បុរសដឹងថាអ៊ុនអន្ទះសាបានជាមិនដឹងចិត្តចៅហ្វាយប្រេះរហែក។

គីម៉ាល់មិនបន្ទោស គេងាកមុខចេញទៅប្រមូលសម្ភារៈនានាទាំងនិយាយស្រាលៗ៖

«មនុស្សស្លាប់បាត់ហើយ! ធ្វើអី និយាយអី ក៏មិនអាចរស់ឡើងមកវិញបានដែរ!»

មិនទាន់ផុតពីមាត់ផងសំឡេងក្នុងទូរសព្ទបន្លឺឡើង៖

«បងស័ក! ខ្ញុំប្រហែលឆ្លងមិនផុតយប់នេះទេបង! បងស័ក សន្យានឹងខ្ញុំ! ត្រូវមើលថែគេ! ប្រពន្ធខ្ញុំជាមនុស្សល្អ! ខ្ញុំធានាថា គេមិនធ្វើឱ្យបងស័កអស់សង្ឃឹមទេ! បងស័កត្រូវថែរក្សាគេ ថ្នាក់ថ្នមគេពេញមួយជីវិតនេះជំនួសប្អូន!»

ប្រុសស្អាតជ្រួញចិញ្ចើមជាមួយភាពស្រងូតក្នុងកែវភ្នែក។ គេងាកមកស្ដាំដៃបន្តិចតែមិនបានសម្លឹងអ៊ុនចំៗទេ។

សំឡេងប្អូនប្រុសមុនពេលស្លាប់ជាអារុធ......វាជាអាវុធពិតណាស់ ព្រោះហោចណាស់អ្នកគួរតែមានឱកាសបាននិយាយជាមួយគេជាចុងក្រោយ។

«រយៈពេលបីខែមកនេះ គាត់ផ្ញើសារមកជានិច្ច!»

អ៊ុននិយាយបន្ថែម ធ្វើឱ្យគីម៉ាល់លើកបាតដៃទាំងទ្វេច្បូតមុខ។

«មានសារច្រើនណាស់ ខ្ញុំមិនហ៊ានចាក់ស្ដាប់ទេបង តែនេះជាសារចុងក្រោយមុនគាត់ស្លាប់!»

សំឡេងមនុស្សជំនិតដើរចូលមក គីម៉ាល់ប្រញាប់និយាយរារាំង៖

«លុបចោលឱ្យអស់ទៅ!»

បញ្ជាគេធ្វើឱ្យអ៊ុនគាំងដំណើរ។

រឿងបណ្ដាំសំខាន់តែប្រតិកម្មថៅហ្វាយរឹតតែសំខាន់ទៅទៀត។

គីម៉ាល់ពោលបន្ថែម៖

«មនុស្សស្លាប់ហើយស្អីក៏ចប់ដែរ!»

គេមិនចង់ឈឺ មិនចង់ប្រឈម មិនចង់អាណោចអនេកចិត្តបានជាគេគេចវេស។ គេបែរក្រោយដើរសំដៅទ្វារ ជាទីដែលមនុស្សជំនិតផ្សេងទៀតកំពុងរង់ចាំដោយទឹកមុខជ្រប់ ស្រងូត។

ពួកគេស្រលាញ់ពិសិដ្ឋ ហើយក៏អាណិតគីម៉ាល់បានជាពួកគេមិនដឹងត្រូវអារកាត់យ៉ាងណា។ សុភាពបុរសនៅភ្នំពេញ មុនស្លាប់បានប្រគល់មនុស្សស្រីជាទីស្រឡាញ់របស់គេមកឱ្យបងប្រុសមើលថែ។ គេធ្វើនេះមិនមានអ្វីខុសទេ ប៉ុន្ដែគីម៉ាល់ឯណានឹងយល់ស្រប?

វុធដែលស្ងៀមយូរហើយដើរមួយៗទៅរកថៅហ្វាយ។ គីម៉ាល់ឈប់ក្បែរនោះ ហាក់រង់ចាំជណ្ដើរយន្តតែក៏មានឫកពាទំនងចង់ស្ដាប់យោបល់វុធដូចគ្នា។ ទោះបីយ៉ាងណា វុធមិនបានឱ្យយោបល់ទេ គេបែរជាផ្ដល់ដំណឹង៖

«បង! គ្នាយើងនៅឯណោះប្រាប់មកមិញថា ខាងជំទាវនារីភា ដេញតាមអ្នកនាងនីដាប្រកិតណាស់! ដូចអត់ស្រួលទេ!»

គីម៉ាល់ចងចិញ្ចើមងាកមករកមនុស្សជំនិត ។ គេមិនបានសួរតែវុធពន្យល់បន្ថែមៈ

«ភរិយាបងសិដ្ឋឈ្មោះនីដា! ទំនងជាមកពីរឿងចែកមរតកខាងជំទាវនារីភាមិនសុខចិត្តក៏កើតជារឿងតាមសម្លាប់!»

«សម្លាប់?»

គីម៉ាល់ហើបមាត់ផ្ទួនសួរទាំងទឹកមុខមួហ្មង។

ឈ្មោះនារីភាគួរឱ្យសៅហ្មងនឹងស្តាប់ណាស់ទៅហើយទម្រាំមកឮពាក្យសម្លាប់ពាក្យអីទៀតនេះអ្នកណាធ្វើចិត្តរីករាយបាន?

## មរតករាប់លាន

«បាយរៀបចំរួចហើយបង!»

អ៊ុនឱនមកប្រាប់ ទាំងលួចដៀងសម្លឹងស្រីស្អាតខាងស្តាំនៃចៅហ្វាយខ្លួន។ វាជាការល្អណាស់ដែលចៅហ្វាយកម្សត់ចិត្តម្នាក់នេះ អាចស្វែងរកឃើញស្នេហាពិតលើមាតុភូមិខ្លួន ប្រហែលជាអាចហាមគេមិនឱ្យរារាំងខ្លួនឯងពីទឹកដីកំណើតដូចកាលពីមុនទៀត។

គីម៉ាល់មិនតបអ្វី បែរជារក្សាស្នាមញញឹម ងាកមកមើលមុខស្រីស្អាត។ នាងកំពុងតែលូកដៃទៅក្រៅបង្អួចទទួលយកសរសៃវាយោបរិសុទ្ធនៃដែនមេគង្គ។

អ៊ុនលួចមើលពួកគេ។

គីម៉ាល់ខានញញឹមតាំងពីពេលណាមកគេមិនចាំទេ តែស្នាមញញឹមនេះជាសក្ខីភាពអំពីអំណាចបេះដូងដែលខាងស្រីកំពុងមានមកលើចៅហ្វាយប្រុសខ្លួន។

គេដឹងថាគីម៉ាល់ធ្លាប់បាននៅលើគ្រែជាមួយមនុស្សស្រីៗស្អាតបំផុតក្នុងលោកនេះ ស៊ឹងពិបាកចាំបានថាប៉ុន្មាននាក់ផង ចំណែកនារីសំពត់លឿងគ្មានអ្វីទុកថាជាកំពូលសម្រស់ឡើយ តែនាងក៏មិនអន់ដែរបើក្រឡេកមើលទៅកែវភ្នែកភ្លឺថ្លានិងច្រមុះកោងស្រួចកំពុងរីកស្រស់ប៉ប្រឹម។

«តស់ ញ៉ាំបាយ!»

សម្តីម្ចាស់ទូកស្រាលៗ សុភាពៗ ធ្វើឱ្យអ៊ុនអស់សំណើចម្នាក់ឯងមុនពេលដកថយយឺតៗទុកឱកាសឱ្យពួកគេ។

«មានបាយញុំាទៀត? ឪខ្ញុំហ្មែន?»

សម្តីសិចស៊ី ស្រួយៗឪៗ នៃនារីស្រុកយើង បណ្តាលចិត្តប្រុសៗប៉ុន្មាននាក់ដែល ខានបានឮច្រើនឆ្នាំមកហើយទោរទន់ នឹកភ្នកថាទោះជាគន្ធាបុប្ផាស្រុកគេ ជះក្លិនស៊ីវិល័យបែបណានៅតែមិនប្រៀបបាននឹងផ្កាស្រុកឯង បានចុះស្នាមជ្រៅក្នុងសរសៃឈាមអ័រម៉ូនយើងឡើយ។

កម្លោះកម្ពុជាមុនក្រោកឡើង ក៏លូកដៃចាប់ម្រាមឆ្វេងប្រាំរបស់ស្រីមកជាមួយ ធ្វើឱ្យនាងភ្ញាក់ក្រញ៉ាងបើកភ្នែកធំៗ មុនពេលប្រកែកដកចេញមកវិញជាបន្ទាន់។

ដៃដល់ណាស់!

នាងគិតតែមិននិយាយ ដោយគ្រាន់តែផ្លាស់ទឹកមុខហើយក្រោកមកសន្សឹមៗហាក់ទោមនស្ស។ បុរសនេះញញឹមឪពីចំហៀងថ្ពាល់ស្រីដែលចេញសរសៃក្រហមព្រោះអៀនលាយចិត្តមិនស្រណុក។

«នៅនេះស្រុកខ្មែរ!»